# សេចក្តីបន្ថែម ក :
# សុវត្ថិភាព និងភាពអាសន្ន



ក្នុងពេលធ្វើការជាមួយ ឬប្រឈមនឹងសារធាតុគ្រោះថ្នាក់នៅកន្លែងធ្វើការ ក្នុងសហគមន៍ ឬក្នុងផ្ទះ ជាការសំខាន់គឺត្រូវមានសុវត្ថិភាពបំផុតតាមដែលអាចធ្វើបាន និងត្រូវត្រៀមលក្ខណៈសម្រាប់ឧប្បត្តិហេតុផ្សេងៗ។ ក្នុងវគ្គនេះមានព័ត៌មានលើប្រធានបទដូចខាងក្រោម :

- បង្កើតផែនការសុវត្ថិភាពសម្រាប់គ្រាអាសន្ន
- សំណុំសម្ភារៈសង្គ្រោះបឋម
- ឧបករណ៍និងសម្លៀកបំពាក់ការពារ
- ម៉ាស់ការពារ
- ការកំពប់សារធាតុគីមី
- ការព្យាបាលគ្រោះថ្នាក់បង្កដោយសារធាតុគីមី
- ការព្យាបាលការរលាក
- ស្ទុក
- ការសង្គ្រោះដង្ហើម (ការផ្តល់ដង្ហើមពីមាត់ទៅមាត់)

សម្ភារៈដែលផ្តល់នៅទីនេះ នឹងជួយអ្នកឲ្យត្រៀមលក្ខណៈសម្រាប់ភាពអាសន្ន ប៉ុន្តែវាមិនមែនជាសៀវភៅណែនាំសម្រាប់ការសង្គ្រោះបឋមពេញលេញទេ។ ដើម្បីត្រៀមលក្ខណៈឲ្យកាន់តែល្អ គួររកការបណ្តុះបណ្តាលផ្នែកសង្គ្រោះបឋម និងការព្យាបាលឧប្បត្តិហេតុសារធាតុគីមី, រកសៀវភៅណែនាំសម្រាប់ការសង្គ្រោះបឋម និងយល់អំពីអត្ថន័យក្នុងសៀវភៅ, និងស្នើសុំបុគ្គលិកសុខាភិបាលក្នុងសហគមន៍ឲ្យជួយអ្នកក្នុងការបង្កើតផែនការសុវត្ថិភាព។

# បង្កើតផែនការសុវត្ថិភាពសម្រាប់ភាពអាសន្ន

ការមានឧបករណ៍ការពារ និងសំណុំសម្ភារៈសង្គ្រោះបឋម គឺជាការសំខាន់មួយ រីឯការយល់ដឹងអំពីអ្វីដែលត្រូវធ្វើក្នុងករណីមានភាពអាសន្ន ឬមានឧប្បត្តិហេតុ ក៏ជាការសំខាន់មួយទៀត។ គ្រប់សហគមន៍ និងគ្រប់កន្លែងធ្វើការទាំងអស់ គួរតែមានផែនការសុវត្ថិភាពមួយសម្រាប់ករណីមានការបញ្ចេញសារធាតុពុល ភ្លើងឆេះ ទឹកជំនន់ ព្យុះ និងភាពអាសន្នដទៃទៀត។

សរសេរបិតអាស័យដ្ឋាននិងលេខទូរស័ព្ទរបស់គ្លីនិកឬមន្ទីរពេទ្យដែលនៅជិតបំផុតនៅទីតាំងកណ្តាលផ្ទះ។ ប្រាកដថាមនុស្សគ្រប់គ្នាដឹងពីកន្លែងរក្សាទុកសំណុំសម្ភារៈសង្គ្រោះបឋម និងសម្ភារៈសម្រាប់ភាពអាសន្នដទៃទៀត និងដឹងពីរបៀបប្រើប្រាស់វា។ ផែនការសុវត្ថិភាពក៏អាចរួមបញ្ចូល ៖

- *ផែនការសម្រាប់ដឹកជញ្ជូនអ្នកមានរបួសនិងមានជំងឺទៅកាន់គ្លីនិកឬមន្ទីរពេទ្យ និងយានយន្តដែលអាចប្រើប្រាស់បានក្នុងភាពអាសន្ន។*
- *ទីតាំងប្រជុំ ដូចជាមណ្ឌលក្នុងសហគមន៍ សាលារៀន ព្រះវិហារ។*
- *ការផ្គត់ផ្គង់ទឹកស្អាតក្នុងគ្រាអាសន្ន។*
- *ទូរស័ព្ទឬអាយកូមសម្រាប់ហៅរកជំនួយ និងដើម្បីប្រកាសអាសន្នដល់អាជ្ញាធរនិងប្រព័ន្ធផ្សព្វផ្សាយ។*
- *បញ្ជីរាយឈ្មោះជនចាស់ជរា ជនពិការ និងអ្នកដទៃទៀតនៅក្នុងសហគមន៍ដែលត្រូវការជំនួយក្នុងករណីមានជម្លៀស។*



ភាពអាសន្នខុសៗគ្នាត្រូវការការឆ្លើយតបផ្សេងៗគ្នាដែរ។ ការយល់ដឹងអំពីការគំរាមកំហែងដែលអាចកើតឡើងបំផុតចំពោះសហគមន៍របស់អ្នក និងការរៀនពីការត្រៀមលក្ខណៈសម្រាប់ការគំរាមកំហែងទាំងនោះ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងផែនការភាពអាសន្ន។

# សំណុំសម្ភារៈសង្គ្រោះបឋម

គ្រប់កន្លែងធ្វើការ ប៉ុស្ត៍សុខភាព និងមណ្ឌលក្នុងសហគមន៍ គួរតែមានសំណុំសម្ភារៈសង្គ្រោះបឋមមួយ ដើម្បីផ្តល់ការព្យាបាលក្នុងករណីមានភាពអាសន្ន។ ដាក់សំណុំសម្ភារៈសង្គ្រោះបឋម នៅក្នុងប្រអប់ដែលមានគម្របជិតល្អ ដើម្បីកុំឲ្យទឹក ធូលី ឬសារធាតុគីមីជ្រាបចូលទៅក្នុងប្រអប់បាន។ ត្រូវប្រាកដថាគ្រប់គ្នានៅក្នុងសហគមន៍ ឬកន្លែងធ្វើការ រួមទាំងបុគ្គលិកថ្មី ដឹងពីទីកន្លែងរបស់ប្រអប់នេះ និងដឹងពីរបៀបប្រើប្រាស់វា។

## គួរដាក់អ្វីខ្លះនៅក្នុងសំណុំសម្ភារៈសង្គ្រោះបឋម



ភួយសម្រាប់ដណ្តប់អ្នករបួសឬអ្នកជំងឺ



ការទឹកផឹក




ទឹកផឹក២លីត្រ



ថ្នាំផ្សងសកម្ម ឬម្សៅថ្នាំផ្សងសកម្ម១ដប (សូមអានទំព័រ258)



សម្លៀកបំពាក់សម្រាប់ផ្លាស់ប្តូរក្នុងករណីឆ្លងឬប៉ះពាល់សារធាតុពុល




អំបិល( សម្រាប់លាយជាមួយទឹកដើម្បីធ្វើឲ្យក្អួត បើមាននរណាម្នាក់ផឹកឬលេបថ្នាំពុល, សូមអានទំព័រ257)



បញ្ជីឈ្មោះសារធាតុគីមីប្រើប្រាស់ក្នុងតំបន់ឬកន្លែងធ្វើការ និងផលប៉ះពាល់របស់វាលើសុខភាព។ ចំពោះថ្នាំសម្លាប់សត្វល្អិត ចូរវាយឈ្មោះមុខដំណាំដែលប្រើប្រាស់ជាមួយវា



ម៉ាស់ថង់ ផ្ទាំងក្រណាត់តូច ឬបន្ទះប្លាស្ទិកក្រាស់មានចោះប្រហោងកណ្តាល សម្រាប់ប្រើប្រាស់ពេលផ្តល់ដង្ហើមពីមាត់ទៅមាត់




បង់បិទដំបៅ ស្បៃឬក្រណាត់ស្អាត និងបន្ទះស្តើងៗសម្រាប់រុំរបួស



ថ្នាំពេទ្យដែលបានចុះបញ្ជីជាថ្នាំបន្សាបជាតិពុលដែលមាននៅលើស្លាកសញ្ញាថ្នាំសម្លាប់សត្វល្អិតឬសារធាតុគីមីដទៃទៀតដែលអ្នកអាចប្រើប្រាស់

សហគមន៍និងកន្លែងធ្វើការ ផ្សេងៗគ្នាត្រូវការសម្ភារៈសង្គ្រោះបឋមខុសៗគ្នាដែរ។ ពិចារណាពីប្រភេទនៃភាពអាសន្នដែលអាចកើតឡើងក្នុងតំបន់របស់អ្នក រួចរៀបចំសំណុំសម្ភារៈសង្គ្រោះបឋមរបស់អ្នកទៅតាមប្រភេទនៃភាពអាសន្ននោះ។ ប្រសិនបើអ្នកប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតឬសារធាតុគីមីដទៃទៀត សូមអានស្លាកសញ្ញារបស់វាដើម្បីស្វែងយល់ថាតើថ្នាំពេទ្យណាខ្លះដែលបានណែនាំឲ្យប្រើជាមួយថ្នាំពុលនេះ។





កន្ត្រៃឬកាំបិតសម្រាប់
កាត់បង់ស្អិត ឬបង់រុំ



ជន្លៀសសម្រាប់យក
បំណែកឬអំបែងចេញ



សៀវភៅណែនាំសម្រាប់
ការសង្គ្រោះបឋម



ដែកអបឬឈើសម្រាប់ទប់ឆ្អឹង
ដែលបាក់ឲ្យនៅនឹង




សាប៊ូមួយដុំ



ក្រែមសម្លាប់មេរោគ
សម្រាប់សម្អាតដំបៅ




ក្រមួនថ្នាំផ្សះដាក់ភ្នែក



ក្រណាត់ស្អាតសម្រាប់ជូតសម្អាតស្បែក
និងជូតផ្តិតសារធាតុគីមីដែលកំពប់លើ



ស្រោមដៃជ័រ ឬប្លាស្ទិកពីរគូ



ប្រាក់បន្តិចបន្តួចឬកាតទូរស័ព្ទ
បិតភ្ជាប់គម្របកញ្ចប់
សម្រាប់ហៅទូរស័ព្ទបន្ទាន់



ក្តារស្នែង ឧបករណ៍សែង ឬក្រណាត់ដណ្តប់
ដើម្បីសែងអ្នករបួសឬអ្នកជំងឺ

# សម្លៀកបំពាក់ និងឧបករណ៍ការពារ

មនុស្សគ្រប់គ្នាគួរតែស្លៀកពាក់សម្លៀកបំពាក់ការពារ ឬហៅថាឧបករណ៍ការពារខ្លួន នៅពេលធ្វើការជាមួយ ឬប្រឈមនឹងនឹងសារធាតុគ្រោះថ្នាក់។ វាជាការទទួលខុសត្រូវរបស់និយោជិកដែលត្រូវផ្តល់ឧបករណ៍ការពារឲ្យកម្មករ។ កម្មករគួរតែទាមទារនយោជិកឲ្យគោរពសិទ្ធរបស់ពួកគេក្នុងការមានសុខភាពនិងសុវត្ថិភាពតាមរយៈការផ្តល់ឧបករណ៍ការពារ និងថែទាំវាក្នុងស្ថានភាពល្អ។

ដើម្បីការពារមនុស្ស សម្លៀកបំពាក់ការពារត្រូវតែសមល្មម និងត្រូវតែបានថែទាំល្អ។ មានគេនិយាយថា ក្នុងប្រទេសក្រីក្រមានឧបករណ៍ការពារបីប្រភេទ : ប្រភេទធំខ្លាំង តូចខ្លាំង និងរហែក។ បើអ្នកគ្មានឧបករណ៍និងសម្លៀកបំពាក់ការពារទេ អ្នកអាចការពារខ្លួនអ្នកដោយពាក់អាវភ្លៀង ឬធ្វើសម្លៀកបំពាក់ការពារដោយខ្លួនឯងដោយធ្វើចេញពីថង់ប្លាស្ទិក។ កាត់ប្រហោងសម្រាប់ក្បាលនិងដៃរបស់អ្នក រួចដាក់ថង់ផ្សេងទៀតនៅលើដៃនិងជើងរបស់អ្នក និងលើប្រអប់ដៃនិងប្រអប់ជើង។




រូបភាពនេះបង្ហាញពីសម្ភារៈការពារគ្រប់ប្រភេទដែលចាំបាច់សម្រាប់ការការពារសារធាតុមានគ្រោះថ្នាក់ភាគច្រើន។ មិនមែនគ្រប់ការងារឬសារធាតុទាំងអស់ សុទ្ធតែត្រូវការសម្ភារៈការពារទាំងនេះនោះទេ ហើយការងារប្រភេទខ្លះទៀត ត្រូវការសម្លៀកបំពាក់និងឧបករណ៍ការពារយ៉ាងពិសេស។

**ចំពោះកសិករដែលប្រឈមនឹងថ្នាំសម្លាប់សត្វល្អិត គួរពាក់ :**






បើគ្មានឧបករណ៍ដកដង្ហើមឬម៉ាស់មុខទេ គេអាចប្រើកន្សែងធំឬក្រមា។ ប៉ុន្តែថ្នាំសម្លាប់សត្វល្អិតនឹង ជាប់លើក្រមាឬកន្សែងដែលសើម ឬមានញើស។ វាធ្វើឲ្យកាន់តែមានគ្រោះថ្នាក់ខ្លាំងជាងមិនមានការការពារមុខទៅទៀត។ ប្រសិនបើអ្នកត្រូវតែប្រើប្រាស់ក្រមាឬកន្សែង ត្រូវលាងជម្រះនិងសម្ងួតឲ្យបានញឹកញាប់ និងត្រូវដឹងថាវាមិនបានផ្តល់ការការពារបានច្រើននោះទេ។

**កម្មករប្រេងនិងរ៉ែ**អាចទទួលបានការការពារល្អប្រសើរ នៅពេលណាគាត់ពាក់ ៖




**អ្នកប្រមូលកាកសំណល់ និងបុគ្គលិកសុខាភិបាល**នៅមន្ទីរពេទ្យ គ្លីនិកសុខភាព និងគ្រឹះស្ថានថែទាំសុខភាពដទៃទៀត គួរពាក់ ៖




ឧបករណ៍និងសម្លៀកបំពាក់ការពារ អាចការពារបានលុះត្រាតែវាស្អាតប៉ុណ្ណោះ។ បន្ទាប់ពីប្រើប្រាស់ម្តងៗ ឬបន្ទាប់ពីបញ្ចប់វេនម្តងៗ ត្រូវលាងសម្អាតស្រោមដៃ ម៉ាស់ វ៉ែនតា និងសម្លៀកបំពាក់និងឧបករណ៍ដទៃទៀត ដើម្បីបង្ការការចម្លងដល់អ្នកប្រើប្រាស់បន្ទាប់ទៀត។

# ម៉ាស់ការពារ

មធ្យោបាយល្អបំផុតដើម្បីបង្ការគ្រោះថ្នាក់បណ្តាលមកពីការដកដង្ហើមចូលនូវសារធាតុគីមី និងកំទេចធូលី គឺត្រូវមានចរន្តខ្យល់ចេញចូលបានល្អក្នុងពេលបំពេញការងារ និងត្រូវពាក់ម៉ាស់ការពារដែលផលិតឡើងសម្រាប់ការពារប្រឆាំងនឹងសារធាតុគីមីដែលអ្នកបំពេញការងារជាមួយ។ ប្រសិនបើអ្នកមានអារម្មណ៍មិនស្រួលខ្លួនដោយសារសារធាតុគីមីខណៈដែលពាក់ម៉ាស់ នោះវាគឺជាសញ្ញាមួយបញ្ជាក់ថា ម៉ាស់លែងមានប្រសិទ្ធភាព ឬបញ្ជាក់ថាអ្នកកំពុងប្រឈមនឹងសារធាតុគីមីនោះឬសារធាតុគីមីផ្សេង តាមរបៀបដទៃទៀត។



### ម៉ាស់ក្រណាត់ឬក្រដាសដែលរលុង

ម៉ាស់បែបនេះនឹងជួយទប់ស្កាត់កំទេចធូលីបានខ្លះ។ វានឹងមិនអាចបញ្ឈប់ការដកដង្ហើមចូលនូវផ្សែងសារធាតុគីមីពុលបានទេ។ ផ្សែងអាចឆ្លងកាត់ក្រដាសនិងក្រណាត់ និងអាចជ្រាបចូលតាមគែមម៉ាស់ដែលរលុង។



### ម៉ាស់ក្រដាសរឹបណែនល្អ

ម៉ាស់ប្រភេទនេះនឹងការពារពីកំទេចធូលីបាន។ ម៉ាស់នេះគួរប៉ះជុំវិញផ្ទៃមុខរបស់អ្នក។ វានឹងមិនបញ្ឈប់ការដកដង្ហើមចូលនូវផ្សែងសារធាតុគីមីពុលបានទេ។ ម៉ាស់ទាំងនេះអាចស្ទះរន្ធ ឬរហែកដាច់យ៉ាងឆាប់ ដូច្នេះត្រូវប្តូរថ្មីពេលម៉ាស់លែងប៉ះជុំវិញមុខ។



### ម៉ាស់ប្លាស្ទិកការពារកំទេចធូលី

ម៉ាស់នេះនឹងការពារកំទេចធូលីបានល្អប្រសើរជាងម៉ាស់ក្រណាត់រលុង ឬម៉ាស់ក្រដាសរឹបណែន។ ម៉ាស់នេះគួរប៉ះជុំវិញផ្ទៃមុខរបស់អ្នក។ វានឹងមិនបញ្ឈប់ការដកដង្ហើមចូលនូវផ្សែងសារធាតុគីមីទេ។



### ឧបករណ៍ដកដង្ហើមជ័រ

ម៉ាស់ជ័រមានតម្រងចម្រោះនេះ អាចការពារអ្នកពីការដកដង្ហើមចូលនូវផ្សែងសារធាតុគីមី។ វាត្រូវរឹបមុខរបស់អ្នកយ៉ាងណែន ដូច្នេះនឹងគ្មានខ្យល់ជ្រាបចន្លោះស្បែកមុខនិងម៉ាស់ទេ។ អ្នកអាចត្រូវការតម្រងចម្រោះផ្សេងៗសម្រាប់សារធាតុគីមីនីមួយៗ និងត្រូវផ្លាស់ប្តូរតម្រងចម្រោះញឹកញាប់។ អ្នកនឹងត្រូវការការបណ្តុះបណ្តាលពិសេសក្នុងការដាក់វាឲ្យរឹបណែន ការប្រើប្រាស់ និងសម្អាតម៉ាស់នេះ។ ម៉ាស់នេះមានសភាពក្តៅ និងមិនមានផាសុកក្នុងការពាក់ទេ។ នៅពេលធ្វើការជាមួយសារធាតុគីមី ត្រូវឈប់សម្រាកឲ្យបានញឹកញាប់នៅក្នុងកន្លែងចំហរនិងមានខ្យល់ចេញចូលល្អ ដែលនៅទីនោះអ្នកអាចដោះម៉ាស់ចេញដោយសុវត្ថិភាព។

## របៀបបង្កើតម៉ាស់ក្រណាត់ដែលមានថ្នាំធ្យូងសកម្ម

ម៉ាស់ដែលអាចផលិតនៅផ្ទះនេះ ត្រូវបានច្នៃប្រឌិតឡើងដោយវេជ្ជបណ្ឌិតម៉ារាមបា ជនជាតិហ្វីលីពីន។ វាអាចផ្តល់ការការពារកំទេចធូលីនិងសារធាតុគីមីបានខ្លះ។

❶ កាត់អាវទ្រនាប់ក្រណាត់មួយចំហៀងដែលមានទ្រនាប់អេប៉ុងខាងក្នុង។



❷ ចោះដកយកទ្រនាប់អេប៉ុងចេញ។



❸ កាត់ក្រដាសតម្រងចម្រោះ ធ្វើជាកូនថង់ក្រដាសមួយ សម្រាប់បង្កើតជាទ្រនាប់ថ្មី ដែលនឹងដាក់ទៅក្នុងអាវទ្រនាប់។ ដាក់កាបូនសកម្មចំនួន១០០ក្រាម ក្នុងថង់ក្រដាសទ្រនាប់នេះ ដោយប្រាកដថាស្រទាប់របស់កាបូនសកម្មនេះរាយស្មើសព្វកន្លែងនៅក្នុងថង់ក្រដាស គឺមិនមែនធ្លាក់នៅតែខាងក្រោមទេ។ ដេរភ្ជិតក្រដាសដើម្បីកុំឲ្យវាកំពប់ចេញ រួចដាក់ចូលទៅក្នុងអាវទ្រនាប់នៅកន្លែងដាក់អេប៉ុង។



❹ ដេរខ្សែយឺតជាប់នឹងអាវទ្រនាប់នេះ ដើម្បីឲ្យវាជាប់នឹងមុខរបស់អ្នក។



គួរសំងិលម៉ាស់នេះក្នុងខ្យល់ នៅចន្លោះពេលប្រើប្រាស់ម្តងៗ។ ប្រសិនបើប្រើប្រាស់ក្នុងពេលបាញ់ស្ព្រ៉ាយ សារធាតុគីមីដែលពុលបំផុត នោះម៉ាស់នេះអាចប្រើប្រាស់បានល្អត្រឹមពីរដង ដែលម្តងៗមានរយៈពេល៤ម៉ោងប៉ុណ្ណោះ។ ត្រូវផ្លាស់ប្តូរកាបូន១សប្តាហ៍ម្តង អាស្រ័យលើប្រភេទសារធាតុគីមីដែលបានប្រឈម និងរយៈពេលដែលពាក់វា។

# ការកំពប់សារធាតុគីមី

មុននឹងលាងសម្អាតសារធាតុគីមីដែលកំពប់ ត្រូវការពារខ្លួនអ្នក ប្រជាជនដែលរស់នៅក្បែរ និងប្រភពទឹកជាមុន។ ប្រសិនបើមានអ្នកណាផ្សេងទៀតដែលត្រៀមលក្ខណៈបានល្អជាងក្នុងការសម្អាតការកំពប់នេះ (អ្នកដែលបានទទួលការបណ្ដុះបណ្ដាលក្នុងការងារនេះ) ចូរស្នើសុំឲ្យគេនោះជួយ។ **ត្រូវពាក់សម្លៀកបំពាក់ការពារជានិច្ចដើម្បីសម្អាតសារធាតុគីមីនោះ!**

## ការកំពប់សារធាតុគីមីតិចតួច

ប្រសិនបើមានសារធាតុគីមីកំពប់តិចតួច នោះជាការសំខាន់ត្រូវគ្រប់គ្រង ទប់ស្កាត់ និងសម្អាតសារធាតុដែលកំពប់នេះ មុនពេលមានអ្នកណាម្នាក់រងគ្រោះ និងមុនពេលដែលសារធាតុគីមីហូរចូលទៅក្នុងផ្លូវទឹក ឬជ្រាបចូលទៅក្នុងដី។



### ការគ្រប់គ្រងការកំពប់

សំខាន់បំផុតគឺត្រូវគ្រប់គ្រងការកំពប់មិនឲ្យមានកាន់តែច្រើនឡើង។ បិតឧបករណ៍ដែលលេចជ្រាប លើកបញ្ឈរធុងដួលឡើងវិញ ឬដាក់ធុងដែលលេចធ្លាយ ចូលក្នុងធុងដែលមិនលេចធ្លាយ។



### ការទប់ស្កាត់

ដាក់ដី ខ្សាច់ ឬអាចម៍រណា, ដីឥដ្ឋ ឬវត្ថុដទៃទៀត ពីលើសារធាតុដែលកំពប់នោះ។ ប្រសិនបើសារធាតុគីមីនោះអាចហើរក្នុងខ្យល់ ត្រូវគ្របវាដោយក្រណាត់ឬផ្ទាំងប្លាស្ទិក។

### ការសម្អាត

យកប៉ែលចូកសារធាតុទាំងនោះដាក់ចូលទៅក្នុងធុង ឬប្រអប់ប្លាស្ទិកក្រាស់។ មិនត្រូវប្រើទឹកទេ ព្រោះវាអាចឲ្យរាលដាល់សារធាតុគីមី ហើយកាន់តែធ្វើឲ្យមានបញ្ហាធំឡើង។ ចោលសារធាតុនោះដោយសុវត្ថិភាព (សូមអានទំព័រ410 ទៅ411)។



## ការកំពប់សារធាតុគីមីច្រើន

នៅតំបន់ខួងប្រេង តំបន់ការងារ និងតំបន់ឧស្សាហកម្ម ដែលមានការប្រើប្រាស់ ឬដឹកជញ្ជូនសារធាតុគីមីយ៉ាងច្រើន ជាការសំខាន់គឺត្រូវត្រៀមលក្ខណៈសម្រាប់ការកំពប់សារធាតុគីមីក្នុងបរិមាណដ៏ច្រើន។

- បង្កើតផែនការភាពអាសន្ន ជាមួយកម្មករ និយោជិក និងប្រជាជនដែលរស់នៅក្បែរ។ ដឹកនាំការប្រជុំឲ្យបានទៀងទាត់ដើម្បីប្រាកដថាគ្រប់គ្នាទាំងអស់យល់ច្បាស់ពីផែនការ។
- បិតឈ្មោះនិងលេខទូរស័ព្ទរបស់ប្រជាជនដែលត្រូវទាក់ទងក្នុងករណីមានការកំពប់។ រាប់បញ្ចូលនូវនិយោជិកឧស្សាហកម្ម គ្លីនិកនិងមន្ទីរពេទ្យ មន្ត្រីសុវត្ថិភាព អាជ្ញាធរ បុគ្គលិកសុខាភិបាល និងប្រជាជនដែលបានបណ្ដុះបណ្ដាលក្នុងការសម្អាតការកំពប់។
- ទុកសេចក្ដីណែនាំ សម្ភារៈ និងឧបករណ៍ការពារសម្រាប់ការសម្អាត ឲ្យមាននៅនឹងតំបន់ការងារ។
- គូសសម្គាល់ផ្លូវដែលអាចរត់គេចពីតំបន់នោះ។
- មានទឹកសុវត្ថិភាពទុកសម្រាប់ប្រើប្រាស់ក្នុងករណីប្រេងឬសារធាតុគីមីដទៃទៀតបានឆ្លងចូលក្នុងប្រភពទឹកក្នុងសហគមន៍។

# ការព្យាបាលគ្រោះថ្នាក់បង្កដោយសារធាតុគីមី

សារធាតុគីមីអាចកំពប់មកលើស្បែក និងសម្លៀកបំពាក់, សាចចូលក្នុងភ្នែក, ឬត្រូវបានលេបចូល ឬដកដង្ហើមស្រូបផ្សែងចូល។ ប្រសិនបើមាននរណាម្នាក់រងគ្រោះ ត្រូវរកជំនួយពីគ្រូពេទ្យឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន។

### ការដកដង្ហើមចូលនូវសារធាតុគីមី

- យកជនរងគ្រោះចេញឆ្ងាយពីតំបន់ដែលគាត់បានដកដង្ហើមចូលនូវសារធាតុពុល ជាពិសេសប្រសិនបើស្ថិតនៅក្នុងកន្លែងបិទជិត។ ប្រសិនបើការកំពប់កើតឡើងក្នុងផ្ទះ ត្រូវបើកបង្អួច និងទ្វារ។
- យកជនរងគ្រោះដាក់ឲ្យត្រូវខ្យល់បរិសុទ្ធ។
- បន្ធូរសម្លៀកបំពាក់គាត់។
- ដាក់ជនរងគ្រោះឲ្យអង្គុយ ឬដេកដោយលើកក្បាលនិងស្មាឡើង។
- ប្រសិនបើជនរងគ្រោះនោះសន្លប់ ត្រូវដាក់គាត់ឲ្យដេកចំហៀង និងប្រាកដថាគ្មានអ្វីស្ទះផ្លូវដង្ហើមគាត់ទេ។



- ប្រសិនបើគាត់មិនមានដង្ហើម ត្រូវផ្ដល់ដង្ហើមពីមាត់ទៅមាត់(សូមអានទំព័រ557)។
- ប្រសិនបើមានសញ្ញានៃបញ្ហាសុខភាព ដូចជាឈឺក្បាល ក្រហាយច្រមុះឬបំពង់ក វិលមុខ ងងុយដេក តឹងក្នុងទ្រូង ចូររកជំនួយពីគ្រូពេទ្យភ្លាម។ យកស្លាកសញ្ញាឬឈ្មោះសារធាតុគីមី ទៅជាមួយអ្នក។

**ការលេបសារធាតុគីមី :**

- ប្រសិនបើជនរងគ្រោះបាត់បង់ស្មារតី ត្រូវដាក់គាត់ឲ្យដេកចំហៀង និងប្រាកដថាគាត់មានដង្ហើម។
- ប្រសិនបើជនរងគ្រោះមិនមានដង្ហើម ត្រូវផ្តល់ដង្ហើមពីមាត់ទៅមាត់ឲ្យបានឆាប់(សូមអានទំព័រ 557)។ ការផ្តល់ដង្ហើមពីមាត់ទៅមាត់ ក៏អាចធ្វើឲ្យអ្នកប្រឈមនឹងសារធាតុគីមីដែរ ដូច្នេះត្រូវខ្ទប់មាត់របស់អ្នកដោយម៉ាស់ប្រហោង ឬបន្ទះក្រណាត់ ឬបន្ទះប្លាស្ទិកក្រាស់ដោយមានចោះប្រហោងកណ្តាល មុនពេលអ្នកចាប់ផ្តើមផ្តល់ដង្ហើមពីមាត់ទៅមាត់។
- ប្រសិនជនរងគ្រោះអាចផឹកបាន ចូរផ្តល់ទឹកស្អាតឲ្យបានច្រើន។
- រកមើលកញ្ចប់សារធាតុគីមី ហើយអានស្លាកសញ្ញាភ្លាម។ ស្លាកសញ្ញានឹងប្រាប់អ្នកថាតើត្រូវធ្វើឲ្យជនរងគ្រោះនោះក្អួតបញ្ចេញសារធាតុគីមីវិញ ឬមិនត្រូវធ្វើ(សូមអានទំព័រ257)។

**នៅពេលសារធាតុគីមីកំពប់លើរាងកាយឬសម្លៀកបំពាក់**

- ប្រសិនបើអាច ត្រូវយកអ្នករបួសចេញពីសារធាតុគីមីកំពប់។
- ដោះសម្លៀកបំពាក់ ស្បែកជើង គ្រឿងអលង្ការទាំងឡាយដែលសារធាតុគីមីកំពប់លើ។ ត្រូវប្រុងប្រយ័ត្នក្នុងពេលដោះអាវយឺត ឬអាវចាក់ ដើម្បីកុំឲ្យសារធាតុគីមីចូលក្នុងភ្នែក។ ជាការល្អបំផុតគួរកាត់សម្លៀកបំពាក់ចោលតែម្តង បើអាច។
- ចូរលាងសម្អាតកន្លែងដែលប៉ះពាល់គីមី ដោយទឹកត្រជាក់រយៈពេលយ៉ាងតិច១៥នាទី។
- ប្រសិនបើសារធាតុគីមីចូលក្នុងភ្នែក ចូរលាងជម្រះដោយទឹកស្អាតរយៈពេល ១៥នាទី។ ទាញត្របកភ្នែកឡើង និងធ្វើចលនាគ្រាប់ភ្នែកជារង្វង់ ដើម្បីឲ្យភ្នែកទាំងមូលត្រូវបានលាងសម្អាត។



- ប្រសិនបើអ្នករបួសឈប់ដកដង្ហើម ចូរផ្តល់ដង្ហើមពីមាត់ទៅមាត់។
- ប្រើប្រាស់កន្ទបដើម្បីបឺតស្រូបសារធាតុគីមី ត្រូវប្រុងប្រយ័ត្នកុំឲ្យសារធាតុគីមីរាលដាលជុំវិញនោះ។
- ប្រសិនបើរាងកាយត្រូវការរលាកដោយសារធាតុគីមី ត្រូវព្យាបាលដូចការរលាកធម្មតាដែរ (សូមអានទំព័រ555)។

# ការព្យាបាលការរលាក



ចំពោះគ្រប់ការរលាកទាំងអស់ :

- បញ្ឈប់ការរលាកដោយដាក់ត្រាំផ្នែកដែលរលាកក្នុងទឹកត្រជាក់ភ្លាម។ បន្តដាក់ឲ្យត្រជាក់យ៉ាងតិច២០នាទី។
- បន្ថយការឈឺចាប់ដោយឲ្យថ្នាំអាស្ពីរីន(aspirin) ឬថ្នាំបំបាត់ការឈឺចាប់ដទៃទៀត។
- បង្ការកុំឲ្យមានស្ទុក(សូមអានទំព័រ556)។

ចំពោះការរលាកតូចតាច មិនចាំបាច់ព្យាបាលទេ។

ចំពោះការរលាកដោយសារធាតុគីមី ការរលាកដោយការភាយកាំរស្មី ការរលាកដោយអគ្គីសនី និងការរលាកដែលបង្កឲ្យមានពងទឹក (ការរលាកកម្រិតទី២) :

- **មិនត្រូវ**យកអ្វីៗដែលជាប់នៅកន្លែងរលាក។
- **មិនត្រូវ**លាបខ្លាញ់ ប៊ឺរ ឬថ្នាំប្រេង។
- **មិនត្រូវ**បំបែកពងទឹក។
- **មិនត្រូវ**បកស្បែកដែលរបក។
- **មិនត្រូវ**ដាក់អ្វីៗលើកន្លែងរលាកដោយសារធាតុគីមី។
- **ត្រូវ**លាងសម្អាតសារធាតុគីមីចេញពីកន្លែងរលាកដោយប្រើទឹកស្អាតភ្លាម។
- **ត្រូវ**រុំកន្លែងរលាកដោយបង់រុំស្ងួតរលីង (ដូចជាស្បៃរុំស្អាត) ប្រសិនបើអាច។
- **ត្រូវ**លាងសម្អាតថ្មមៗដោយទឹកស្អាត ត្រជាក់ និងដោយសាប៊ូធម្មតា ប្រសិនបើពងទឹកទាំងនោះបែក។ អាចទុកឲ្យកន្លែងរលាកចំហរបាន លុះត្រាតែអ្នកស្ថិតនៅកន្លែងស្អាត គ្មានសត្វល្អិត កំទេចធូលី ឬផ្សែងគីមី។
- **ត្រូវ**ចោលសម្លៀកបំពាក់ដែលអាចឆ្លងដោយសារធាតុគីមី ឬបោកគក់វាដាច់ដោយឡែកពីសម្លៀកបំពាក់ដទៃទៀត។
- **ត្រូវ**លាបទឹកឃ្មុំលើកន្លែងរលាកតូចតាច។ ទឹកឃ្មុំអាចបង្ការនិងបញ្ឈប់ការក្លាយរោគ និងធ្វើឲ្យកាន់តែឆាប់ជាសះស្បើយ។ លាងសម្អាតទឹកឃ្មុំចាស់ចេញថ្មមៗ រួចលាបទឹកឃ្មុំថ្មី យ៉ាងតិច២ដងក្នុង១ថ្ងៃ។

បន្ទាប់មកនាំជនរងគ្រោះទៅជួបបុគ្គលិកសុខាភិបាល ឬមន្ទីរពេទ្យ ឲ្យបានឆាប់តាមដែលអាចធ្វើបាន។

បញ្ជូនជនរងគ្រោះទៅកាន់មន្ទីរពេទ្យ ប្រសិនបើអ្នកគិតថាគេរលាកនៅផ្លូវខ្យល់។ សញ្ញារបស់វាមាន :

- ការរលាកនៅមាត់ និងច្រមុះ ឬរលាកនៅក្នុងមាត់។
- វង្វេងវង្វាន់ស្មារតី សន្លប់ ឬក្អកយ៉ាងខ្លាំងពេលស្រូបផ្សែងធម្មតាចូល។

ម្យ៉ាងទៀត ត្រូវនាំអ្នកជំងឺទៅកាន់មន្ទីរពេទ្យដែរ បើគេមានការរលាកធ្ងន់ធ្ងរនៅលើមុខ ភ្នែក ប្រអប់ដៃ ប្រអប់ជើង ឬប្រដាប់បន្តពូជ។

មនុស្សគ្រប់គ្នាដែលមានការរលាកខ្លាំង អាចចូលក្នុងស្ថានភាពស្ទុកយ៉ាងងាយ(សូមអាននៅទំព័របន្ទាប់) ដោយសារតែមានការឈឺចាប់ គួបផ្សំគ្នានឹងការភ័យខ្លាច និងបាត់បង់សារធាតុរាវពីរាងកាយតាមកន្លែងរលាក។ ធ្វើឲ្យជនរងគ្រោះមានផាសុក និងនិយាយផ្តល់កម្លាំងចិត្តដល់គាត់ បន្ថយការឈឺចាប់ ព្យាបាលស្ទុក និងផ្តល់ទឹកផឹកឲ្យបានច្រើន។

# ស្ទុក

ស្ទុកគឺជាស្ថានភាពគំរាមកំហែងដល់ជីវិត ដែលអាចជាលទ្ធផលនៃការរលាកយ៉ាងធំ បាត់បង់ឈាមច្រើន ជំងឺធ្ងន់ធ្ងរ ខ្សោះជាតិទឹក ប្រតិកម្មអាឡែហ្ស៊ីធ្ងន់ធ្ងរ ការប្រឈមនឹងសារធាតុពុលយ៉ាងស្រួចស្រាល់ ឬ ស្ថានភាពអាសន្នដទៃទៀត។

## សញ្ញានៃស្ទុក

- វង្វេងវង្វាន់ស្មារតី ខ្សោយ វិលមុខ ឬសន្លប់
- ជីពចរខ្សោយនិងញាប់
- បែកញើសត្រជាក់ : ស្បែកស្លេក ត្រជាក់ និងសើម
- សម្ពាធឈាមធ្លាក់ចុះទាបយ៉ាងគ្រោះថ្នាក់

## ដើម្បីបង្ការឬព្យាបាលស្ទុក

នៅសញ្ញាដំបូងនៃស្ទុក ឬនៅពេលមានការប្រឈមនឹងស្ទុក :

- ដាក់ជនរងគ្រោះឲ្យដេក ដោយជើងខ្ពស់ជាងក្បាលបន្តិច ដូចរូបនេះ : →



- បញ្ឈប់ការហូរឈាម និងព្យាបាលរបួសផ្សេងៗ។
- ប្រសិនបើជនរងគ្រោះមានអារម្មណ៍ត្រជាក់ ចូរដណ្តប់ភួយឲ្យគាត់។
- ប្រសិនបើជនរងគ្រោះមិនអាចផឹកបាន ចូរឲ្យគាត់ក្រេបម្តងបន្តិចៗ។ ប្រសិនបើគាត់ខ្សោះជាតិទឹក ត្រូវផ្តល់ទឹកឲ្យបានច្រើន និងភេសជ្ជៈបង្គ្រប់ជាតិទឹក(សូមអានទំព័រ53)។
- ប្រសិនបើជនរងគ្រោះមានការឈឺចាប់ ចូរផ្តល់ថ្នាំអាស្ពីរីន(aspirin) ឬថ្នាំបំបាត់ការឈឺចាប់ដទៃទៀត ប៉ុន្តែមិនត្រូវឲ្យថ្នាំដែលមានជាតិរម្ងាប់អារម្មណ៍ទេ ដូចជា កូដេអ៊ីន(codeine)ជាដើម។
- ធ្វើចិត្តឲ្យត្រជាក់ ហើយនិយាយផ្តល់កម្លាំងចិត្តដល់ជនរងគ្រោះ។

ប្រសិនបើជនរងគ្រោះសន្លប់ :

- ដាក់គាត់ឲ្យដេកចំហៀង ដោយឲ្យក្បាលទាប ផ្អៀងខ្នងទៅចំហៀង(សូមមើលរូបខាងលើ)។ ប្រសិនគាត់ហាក់ដូចជាឈ្លក់ ចូរយកម្រាមដៃទាញអណ្តាតគាត់មកមុខ។
- ប្រសិនបើគាត់មានកំអួត ចូរសម្អាតមាត់របស់គាត់ភ្លាម។
- មិនត្រូវឲ្យអ្វីតាមមាត់ទេ រហូតដល់គាត់មានស្មារតីឡើងវិញ។
- **ស្វែងរកជំនួយពីគ្រូពេទ្យ។**

# ការសង្គ្រោះដង្ហើម (ការផ្តល់ដង្ហើមពីមាត់ទៅមាត់)

ជនរងគ្រោះអាចស្លាប់ក្នុងរយៈពេល៤នាទី ប្រសិនបើគាត់គ្មានដង្ហើម។ ប្រសិនបើជនរងគ្រោះឈប់ដកដង្ហើមដោយមូលហេតុណាមួយ ចូរផ្តល់ដង្ហើមពីមាត់ទៅមាត់ភ្លាម! ប្រសិនបើអ្នកនោះលេបសារធាតុគីមី ការផ្តល់ដង្ហើមតាមមាត់ ក៏អាចធ្វើឲ្យអ្នកប្រឈមនឹងសារធាតុគីមីដែរ ដូច្នេះមុនចាប់ផ្តើមផ្តល់ដង្ហើមពីមាត់ទៅមាត់ ត្រូវខ្ទប់មាត់របស់អ្នកដោយម៉ាស់ចង់ ឬបន្ទះក្រណាត់ ឬបន្ទះប្លាស្ទិកចោះប្រហោងកណ្តាល។



**ជំហានទី១ :** យកម្រាមដៃយកចេញវត្ថុផ្សេងៗដែលជាប់ក្នុងមាត់ឬបំពង់កឲ្យលឿនបំផុត។ ទាញអណ្តាតមកមុខ។ ប្រសិនបើមានស្លេសក្នុងបំពង់ក ត្រូវព្យាយាមសម្អាតវាឲ្យបានឆាប់បំផុត។

**ជំហានទី២ :** ដាក់ជនរងគ្រោះឲ្យដេកផ្ងារឲ្យបានឆាប់ និងថ្នមៗ។ ទាញក្បាលគាត់ទៅក្រោយថ្នមៗ រួចទាញថ្គាមរបស់គាត់ទៅមុខ។



**ជំហានទី៣ :** យកម្រាមដៃច្របាច់ច្រមុះគាត់ បើកមាត់គាត់ ដាក់មាត់របស់អ្នកលើមាត់របស់គាត់ ហើយផ្លុំខ្យល់ឲ្យខ្លាំងចូលទៅក្នុងសួតរបស់គាត់ ឲ្យឃើញទ្រូងរបស់គាត់ប៉ោងឡើង។ ចាំមួយភ្លែតដើម្បីឲ្យខ្យល់ចេញមកវិញ រួចផ្លុំថែមទៀត។ ធ្វើសារចុះសារឡើង ប្រហែល៥វិនាទីម្តង។ ចំពោះទារក និងកុមារតូចៗ ចូរដាក់មាត់របស់អ្នកលើច្រមុះនិងមាត់ រួចផ្តល់ដង្ហើមថ្នមៗប្រហែល៣វិនាទីម្តង។ បន្តសង្គ្រោះដង្ហើមរហូតដល់គាត់អាចដកដង្ហើមដោយខ្លួនគាត់បាន ឬរហូតប្រាកដថាគាត់បានស្លាប់ហើយ។ ជួនកាលអ្នកត្រូវតែព្យាយាមផ្តល់ដង្ហើមរហូតដល់១ម៉ោងឬលើស។



**ចំណាំ :** បើមិនមានដំបៅចំហរ ឬការហូរឈាមក្នុងមាត់ទេ នោះការឆ្លងមេរោគអេដស៍តាមរយៈការផ្តល់ដង្ហើមពីមាត់ទៅមាត់ គឺមិនអាចកើតឡើងបានឡើយ។